

**វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម**

**ដេប៉ាតឺម៉ង់**..............................................

# សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ

## កម្រិត ១

## ម៉ូឌុល/មុខវិជ្ជា ៖ ជំនាញទន់

## មេរៀនទី ១៖ មនសិការវិជ្ជាជីវៈ និងការធ្វើការងារជាក្រុម

# គោលដៅមេរៀន

ក្រោយបញ្ចប់មេរៀននេះ សិក្ខាកាម សិស្ស និស្សិតនឹងមានសមត្ថភាព៖

- ➢ កំណត់អត្ថន័យនៃពាក្យ «មនសិការវិជ្ជាជីវៈ»។
- ➢ យល់ដឹងអំពីអត្ថប្រយោជន៍នៃមនសិការវិជ្ជាជីវៈ។
- ➢ កំណត់សារៈសំខាន់នៃការងារ និងសម្គាល់ចរិតលក្ខណៈរបស់បុគ្គលិក។
- ➢ កំណត់តម្លៃ និងសារៈសំខាន់នៃការងារជាក្រុម។

# មេរៀនទី១៖ មនសិការវិជ្ជាជីវៈ និងការធ្វើការងារជាក្រុម

## ១. សេចក្តីផ្តើម

➢មនសិការវិជ្ជាជីវៈ និងការបំពេញការងារជាក្រុម គឺជាមុខវិជ្ជាដ៏សំខាន់នាពេលបច្ចុប្បន្ន ដែលអាចចាត់ទុកថាជាថ្នាំដ៏ស័ក្តិសិទ្ធិសម្រាប់ព្យាបាលជំងឺប្រថុយប្រថានរបស់ថៅកែ ឬបុគ្គលិកភាគច្រើនដែលកំពុងជួបឧបសគ្គ ឬជាត្រីវិស័យសម្រាប់ដឹកនាំបុគ្គលណាដែលមានបំណងឆ្ពោះទៅរកភាពជាអ្នកដឹកនាំ និងបុគ្គលិកឆ្នើម។

# ២. តើអ្វីជាមនសិការវិជ្ជាជីវៈ?



# ២.១. និយមន័យ

- មនសិការវិជ្ជាជីវៈ មានន័យថាការបំពេញមុខងារប្រកបរបរចិញ្ចឹមជីវិតដោយការយកចិត្តទុកដាក់។ រួមបញ្ចូលនូវការយល់ដឹង ក្រមសីលធម៌ និងបញ្ហាប្រឈម និងផលប៉ះពាល់នៃវិជ្ជាជីវៈរបស់បុគ្គលម្នាក់ៗមកលើខ្លួនឯង អ្នកដទៃ និងសង្គមផងដែរ។
- មនសិការវិជ្ជាជីវៈ ជួយឱ្យអ្នកជំនាញធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ការពេញចិត្ត និងសុខុមាលភាព ក្នុងអាជីពរបស់ពួកគេ។

# ២.២. សារៈសំខាន់នៃការងារ

- ហេតុអ្វីយើងត្រូវធ្វើការងារ?



# ២.២. សារៈសំខាន់នៃការងារ

- ការងារគឺជាប្រភពនៃចំណូលសេដ្ឋកិច្ចក្នុងគ្រួសាររបស់មនុស្សម្នាក់ៗ ដែលមិនអាចខានបាន។
- ការងារ នាំឱ្យមនុស្សស្គាល់ពីតម្លៃខ្លួនឯង មានសមត្ថភាពពិតប្រាកដ និងមានភាពម្ចាស់ការលើខ្លួនឯង។
- សរុបជារួមមក បានជាយើងត្រូវការធ្វើការងារ ព្រោះការងារជាកាតាលីករជំរុញ និងកំណត់បាននូវគុណតម្លៃសម្រាប់មនុស្សម្នាក់ៗនៅក្នុងសង្គម។



# ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

- ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិតម្នាក់ៗនៅក្នុងអង្គភាព គឺពិតជាមានសារៈសំខាន់ណាស់ដើម្បីទទួលបានប្រសិទ្ធភាពការងារខ្ពស់។



# ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

## ក-ភាពស្មោះត្រង់



# ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

- ភាពស្មោះត្រង់ជួយឱ្យយើងបង្កើតទំនុកចិត្ត ការគោរព និងទំនាក់ទំនងវិជ្ជមានជាមួយអ្នកដទៃ ដើម្បីជៀសផុតពីបញ្ហា និងជម្លោះដែលអាចកើតឡើងដោយការកុហក ឬបោកប្រាស់។
- ដូចនេះភាពស្មោះត្រង់របស់បុគ្គលិក គឺជាភាពចាំបាច់របស់អង្គភាពដែលត្រូវមានចាប់ពីកម្រិតថ្នាក់ដឹកនាំ រហូតដល់បុគ្គលិកថ្នាក់ទាប។

# ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

## ខ-ភាពទៀងទាត់



## ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

- ភាពទៀងទាត់ សំដៅទៅលើពេលវេលា ដូចជាម៉ោងពេលបំពេញការងារ ការណាត់ជួប ការឆ្លើយតបសារទំនាក់ទំនងជាដើម។
- សរុបមកមនុស្សគ្រប់រូបត្រូវចេះគ្រប់គ្រងពេលវេលា និងគោរពភាពទៀងទាត់ ពីព្រោះវាមានឥទ្ធិពលវិជ្ជមានទៅលើផលិតភាពការងារ ការលើកទឹកចិត្ត ការពេញចិត្ត និងសុខុមាលភាពរបស់និយោជិត និងនិយោជក។

# ២.៣. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

## គ-ការមានរបៀប និងការសម្អាត






➢ អនាម័យនាំមកនូវសុខភាពល្អ អារម្មណ៍ស្រស់ស្រាយ មានទ្រព្យសម្បត្តិ និងសុភមង្គល។

# ៣. ការបំពេញការងារជាក្រុម

## ៣.១ និយមន័យ

➢ ការបំពេញការងារជាក្រុម ជាបណ្តុំនៃមនុស្សដែលធ្វើការជាមួយគ្នា ដើម្បីសម្រេចគោលដៅរួម។ វាគឺជាជំនាញដ៏មានតម្លៃបំផុត នៅក្នុងកន្លែងធ្វើការ ព្រោះវាអាចបង្កើនផលិតភាពការងារ ភាពច្នៃប្រឌិត និងក្រមសីលធម៌។



# ៣.២ សារៈសំខាន់នៃការបំពេញការងារជាក្រុម

➢ ដើម្បីទទួលបាននូវប្រសិទ្ធភាពការងារទាមទារឱ្យសមាជិកក្រុមមានការសហការដូចខាងក្រោម៖

- **បង្កើតគំនិត និងការច្នៃប្រឌិត** ដែលបានមកពីការពិភាក្សា ផ្លាស់ប្តូរមតិយោបល់ ក្នុងការកែលម្អ ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន។



# ៣.២ សារៈសំខាន់នៃការបំពេញការងារជាក្រុម

- **បង្កើនផលិតផល និងសេវាកម្ម** តាមរយៈការសហការគ្នាស៊ីចង្វាក់ រហូតអាចចេញជាសមិទ្ធផលនៃការច្នៃប្រឌិត និងការបង្កើតថ្មី។
- **បង្កើតមានភាពស្និតស្នាល និងដោះស្រាយភាពតានតឹង** ឱ្យតម្លៃមតិយោបល់ខុសគ្នា មានន័យថាប្រាប់ពីយោបល់របស់ខ្លួន និងស្តាប់ពីមតិយោបល់របស់សមាជិកផ្សេងៗទៀត។



# ៣.២ សារៈសំខាន់នៃការបំពេញការងារជាក្រុម

- **លើកកម្ពស់សីលធម៌បុគ្គល និងក្រុមការងារ** ជាការស្វែងយល់ពីសីលធម៌ និងសុជីវធម៌ របស់សមាជិកគំរូ ។



- **បង្កើនវិជ្ជាជីវៈ** ជាការទទួលយក និងផ្លាស់ប្តូរចំណេះដឹងបទពិសោធន៍ ដល់គ្នាទៅវិញទៅមកក្នុងន័យបង្កើនសមត្ថភាពវិជ្ជាជីវៈសមាជិកក្រុម។

# ៣.៣ កំហុសក្នុងការបំពេញការងារក្រុម និងដំណោះស្រាយកំហុសឆ្គង

- ➢ កំហុសមួយចំនួនក្នុងការងារជាក្រុម ដែលអ្នកអាចជួបប្រទះនៅកន្លែងធ្វើការគឺ៖

- **ខ្វះភាពច្បាស់លាស់៖** ភាពមិនច្បាស់លាស់ធ្វើឲ្យសមាជិកក្នុងក្រុមខ្ជះខ្ជាយពេលវេលា ធនធាន និងថាមពលលើការងារដែលមិនពាក់ព័ន្ធ។
- **បញ្ហាទំនុកចិត្ត៖** ការមិនទុកចិត្តគ្នាអាចធ្វើឲ្យមានភាពស្ទាក់ស្ទើរក្នុងការចែករំលែកព័ត៌មាន គំនិត យោបល់ ឬមតិកែលម្អជាដើម។
- **ជម្លោះបុគ្គលិកលក្ខណះ៖** សមាជិកក្រុមមានបុគ្គលិកលក្ខណៈ គុណតម្លៃ ជំនឿ ឬទម្រង់ការងារខុសៗគ្នា ដូច្នេះពួកគេអាចមិនយល់ស្របនឹងគ្នា ដែលបង្កើតជាភាពតានតឹងក្នុងក្រុម។

# ៣.៣ កំហុសក្នុងការបំពេញការងារក្រុម និងដំណោះស្រាយកំហុសឆ្គង

- **កង្វះខាតព័ត៌មាន៖** វាអាចនឹងបណ្ដាលឱ្យខកខានឱកាស បង្កើតកំហុស ឬនាំឱ្យមានការយឺតយ៉ាវក្នុងការងាររបស់ក្រុម។
- **ភាពត្រេកត្រអាល៖** ពួកគេអាចបាត់បង់ការលើកទឹកចិត្ត គំនិតផ្តួចផ្តើម ឬការបង្កើតថ្មីក្នុងការងាររបស់ពួកគេ។

# ៣.៣ កំហុសក្នុងការបំពេញការងារក្រុម និងដំណោះស្រាយកំហុសឆ្គង

- ដំណោះស្រាយកំហុសឆ្គងការងារមានដូចជា៖

  - **ពិនិត្យមើលហេតុ និងផល ឱ្យបានច្បាស់លាស់** ៖ ជៀសវាងនូវការប្រកាន់ ឬចាប់កំហុសគ្នា។

  - **អត់ឱន និងផ្តល់ឱកាសកែខ្លួន** ៖ បើឃើញអ្នកដទៃមានកំហុស ត្រូវចេះប្រាប់ដើម្បីឱ្យគាត់ដឹងនឹងកែលម្អទាន់ពេលវេលា។

  - **លើកទឹកចិត្តគាំទ្រ និងជំរុញ** ៖ ជាការបង្កើតបរិយាកាសរីករាយ ផ្តល់កម្លាំងចិត្ត និងឱកាសឱ្យសមាជិកក្រុម។

  - **ដោះស្រាយបញ្ហាភ្លាមៗ**៖ ដើម្បីកុំឱ្យបញ្ហាកាន់តែធំ រហូតក្លាយជាអំពើហិង្សា។

# ៣.៣ ភ្នំហ្សក្លួចការបំពេញការងារក្រុម និងដំណោះស្រាយកំហុសឆ្គង

- **រំងាប់អារម្មណ៍៖** ដោយនៅស្ងៀមស្ងាត់ម្នាក់ឯង ជួបជុំមិត្តភក្តិជជែកគ្នាលេង ស្តាប់បទចម្រៀង និងលេងកីឡាជាដើម។

# ៣.៤ ទំនួលខុសត្រូវក្នុងការបំពេញការងារឱ្យសម្រេចបានជោគជ័យ

➢ សមាជិកក្រុមនីមួយៗត្រូវមានការទទួលខុសត្រូវដូចជា៖

- **ស្គាល់តួនាទីខ្លួន៖** អ្នកដឹកនាំក្រុមត្រូវរៀបចំរចនាសម្ព័ន្ធការងារឱ្យបានច្បាស់លាស់និងណែនាំដល់សមាជិកក្រុម។
- **ធ្វើតាមផែនការ ឬគោលដៅការងារ៖** ដោយអនុវត្តតាមការកំណត់ និងមធ្យោបាយផ្សេងៗ។
- **ការតាំងចិត្តបំពេញការងារ៖** ការចែករំលែកគំនិត និងការប្រាស្រ័យទាក់ទងគ្នាជាផ្លូវមួយ។
- **ការអត់ឱនអធ្យាស្រ័យ៖** គឺជាការជួយបុគ្គលដែលមានស្ថានភាពផ្សេងៗគ្នា។

# ៣.៤ ទំនួលខុសត្រូវក្នុងការបំពេញការងារ ឱ្យសម្រេចបានជោគជ័យ

- **ការត្រួតពិនិត្យការងារខ្លួនឯង និងក្រុមជាប្រចាំ៖** វាយតម្លៃសកម្មភាពដែលបានអនុវត្តកន្លងមក ធៀបទៅនឹងផែនការកំណត់។

# ៤. មនុស្សដែលប្រកបដោយមនសិការវិជ្ជាជីវៈ

- ស្រឡាញ់ការងារ។
- ចំណង់ចំណូលចិត្តក្នុងការបំពេញការងារ។
- និយតភាពក្នុងការងារបំពេញការងារ(ភាពទៀងទាត់)។
- ភាពវាងវៃ និងស្មារតីច្នៃប្រឌិត។
- ប៉ិនប្រសព្វ និងការដោះស្រាយក្នុងការងារ។
- គំនិតរីកចម្រើន និងកំណែលម្អ៕

# សង្ខេបមេរៀនឡើងវិញ

មេរៀនបង្រៀនថ្ងៃនេះ និយាយអំពី៖

- មនសិការវិជ្ជាជីវៈ
- សារៈសំខាន់នៃការងារ
- ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត
- ការបំពេញការងារជាក្រុម។

# កិច្ចការផ្ទះ/សំណួរ

១. តើអ្នកយល់ដូចម្តេចចំពោះសមត្ថភាពជំនាញរបស់ខ្លួន?

២. តើអ្វីជាកត្តាជំរុញឲ្យអ្នកប្រឹងប្រែងបំពេញការងារ?

៣. តើការបំពេញការងារជាក្រុមមានសារៈសំខាន់ដែរឬទេ?




ឯកសារប្រើប្រាស់ផ្ទៃក្នុង-ITI_V01010124